# 6 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ

# ការបែងចែកដីជាតំបន់ និងការប្រើប្រាស់ដីធ្លី

ប្រសិនបើលោកអ្នកចង់ឲ្យមានការផ្លាស់ប្តូរទៅនឹងបរិវេណដីធ្លីរបស់លោកអ្នក ឬកែប្រែវិធីដែលលោកអ្នកប្រើប្រាស់ដីធ្លីរបស់លោកអ្នក លោកអ្នកប្រហែលជាត្រូវការដាក់ពាក្យសុំការអភិវឌ្ឍន៏ (DA) មួយទៅសាលាក្រុងរបស់លោកអ្នក។

គេត្រូវការពាក្យសុំអភិវឌ្ឍន៏ មុនការអភិវឌ្ឍន៏ណាមួយអាចមានដំណើរការទៅមុខ។ ប្រសិនបើសាលាក្រុងទទួលយល់ព្រមពាក្យសុំអភិវឌ្ឍន៏ហើយនោះ លោកអ្នកនឹងបានទទួលច្បាប់អនុញ្ញាតយល់ព្រមដើម្បីធ្វើការអភិវឌ្ឍន៏។ មុនការសាងសង់អាចចាប់ផ្តើមដំណើរការទៅមុខ លោកអ្នកនឹងត្រូវដាក់ពាក្យសុំសញ្ញាបត្រសាងសង់មួយ។

ឧទាហរណ៏ខ្លះៗអំពីអ្វីដែលអាចតម្រូវឲ្យមានពាក្យសុំការអភិវឌ្ឍន៏ មានរួមទាំងសាងសង់រោងចំការ ការសាងសង់ទំនប់ទឹក ការផ្លាស់ប្តូរប្រភេទចំការមួយទៅប្រភេទចំការមួយទៀត ហើយនិងការដាក់បន្ថែមនូវរងដំណាំថ្មីសំរាប់ដំណាំ។



NSW DPI, Virginia Brunton

**អ្វីដែលលោកអ្នកអាចធ្វើបាននៅក្នុងបរិវេណដីធ្លីរបស់លោកអ្នក ត្រូវបានកំណត់ដោយការបែងចែកដីជាតំបន់របស់លោកអ្នក ហើយនិងគំរោងបរិដ្ឋានក្នុងតំបន់ (Local Environment Plan)។ គេនឹងមិនយល់ព្រមទៅលើការដាក់ពាក្យសុំរបស់លោកអ្នក ចំពោះអ្វីដែលពុំបានអនុញ្ញាតនៅក្នុងការបែងចែងដីជាតំបន់របស់លោកអ្នកឡើយ។**



NSW DPI, Steven Honeywood

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

គំរោងបរិដ្ឋានក្នុងតំបន់បង្ហាញប្រាប់អំពីការប្រើប្រាស់ដីធ្លីដែលបានបែងចែក សំរាប់គ្រប់ទាំងដីធ្លីនៅតាមកន្លែងរដ្ឋាភិបាលក្នុងតំបន់។ តំបន់ទាំងនេះមានរួមទាំងដីធ្លីប្រើប្រាស់សំរាប់ទីជនបទ ដីធ្លីប្រើប្រាស់សំរាប់រស់នៅ ហើយនិងដីធ្លីប្រើប្រាស់សំរាប់ពាណិជ្ជកម្ម។ សំរាប់តំបន់នីមួយៗ គំរោងបរិដ្ឋានក្នុងតំបន់នឹងប្រាប់លោកអ្នកថាតើសកម្មភាពទាំងឡាយណាដែលបានអនុញ្ញាតឲ្យមាននៅតាមដីធ្លីរបស់លោកអ្នកដោយមាន ឬគ្មានការអនុញ្ញាតពីសាលាក្រុង។

ឧទាហរណ៏ នៅតាមកន្លែងដែលបានបែងចែកដីជា Rural 1(a) (តំបន់សំរាប់ទីជនបទ) សាលាក្រុងប្រហែលជាអនុញ្ញាតឲ្យមានរោងចិញ្ចឹមសត្វមាន់សំរាប់លក់ ក៏ប៉ុន្តែនៅតាមកន្លែងដែលបានបែងចែកដីជា Residential 2(a) (តំបន់សំរាប់រស់នៅ) សាលាក្រុងហាមប្រាមមិនឲ្យមានរោងចិញ្ចឹមមាន់សំរាប់លក់ឡើយ។ តំបន់សាលាក្រុងនីមួយៗប្រហែលជាមានលក្ខណៈខុសពីគ្នា។ សកម្មភាពនានាដែលបានអនុញ្ញាតឲ្យធ្វើដោយពុំចាំបាច់មានពាក្យសុំការអភិវឌ្ឍន៏ (DA) នៅតាមកន្លែងមួយ ប្រហែលជាគ្មានការអនុញ្ញាតនៅតាមកន្លែងមួយទៀតឡើយ។

ប្រសិនបើលោកអ្នកដឹងអំពីការបែងចែកដីជាតំបន់នៃដីធ្លីរបស់លោកអ្នក និងអំពីអ្វីដែលមានការអនុញ្ញាត ការនេះនឹងផ្តល់នូវឱកាសប្រសើរក្នុងការទទួលបាននូវការអនុញ្ញាតយល់ព្រមលើការដាក់ពាក្យសុំរបស់លោកអ្នក។

**ដើម្បីទទួលព័ត៌មានច្រើនថែមទៀតអំពីដំណើរការដាក់ពាក្យសុំការអភិវឌ្ឍន៏ DA សូមអានសន្លឹកព័ត៌មានសំរាប់អ្នកដំណាំលក់តាមទីផ្សារ លេខ 2។**

ដើមឈើ: សាលាក្រុងនីមួយៗមានច្បាប់រក្សាទុកដើមឈើដែលហាមឃាត់កុំឲ្យមានការកាប់ចេញ ការកាត់មែកតូចតាច ការកាត់សំបក ឈើព័ទ្ធជុំវិញដើមឈើ ការកាត់កំបុតចុងឈើ ការធ្វើឲ្យដើមឈើស្វិតស្រពោន ឬធ្វើឲ្យខូចខាតដល់ដើមឈើណាមួយ លើកលែងតែដើមឈើនោះនាំឲ្យមានគ្រោះថ្នាក់ដល់ជីវិត ឬទ្រព្យសម្បត្តិ។ សណ្ឋានដីធ្លីឯកជនត្រូវតែបានពិនិត្យមើល ហើយទទួលការអនុញ្ញាតយល់ព្រមពីសាលាក្រុងជាមុនសិន មុននឹងយកដើមឈើណាមួយចេញពីដីធ្លីនោះ លុះត្រាតែបានលើកលែងចេញពីគំរោងបរិដ្ឋានក្នុងតំបន់។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST